**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គិសនីកម្ពុជា**
**គណៈកម្មាធិការលទ្ធកម្ម**
លេខ: .....១១៣៣ PC.អក

## សេចក្តីជូនដំណឹង
## ស្តីពី

ការផ្គត់ផ្គង់គ្រឿងបន្លាស់ ជូន រោងចក្រអគ្គិសនីខេត្តចំនួន ០៩ (អគ្គិសនី មណ្ឌលគិរី កំពត ស្ទឹងត្រែង រតនគិរី បន្ទាយមានជ័យ ព្រៃវែង តាកែវ បាត់ដំបង និងស្វាយរៀង) នៃ នាយកដ្ឋានផលិតកម្ម.

អគ្គិសនីកម្ពុជាសូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថា ៖ អគ្គិសនីកម្ពុជា នឹងដាក់ឲ្យដេញថ្លៃជាសាធារណៈ ដើម្បីផ្គត់ផ្គង់គ្រឿងបន្លាស់ ជូន រោងចក្រអគ្គិសនីខេត្តចំនួន ០៩ (អគ្គិសនី មណ្ឌលគិរី កំពត ស្ទឹងត្រែង រតនគិរី បន្ទាយមានជ័យ ព្រៃវែង តាកែវ បាត់ដំបង និងស្វាយរៀង) នៃ នាយកដ្ឋានផលិតកម្ម ។

អគ្គិសនីកម្ពុជា បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្មអគ្គិសនីកម្ពុជា ដែលមានអាសយដ្ឋាន: អាគារលេខ២ ផ្លូវព្រះយុគន្ធរ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញចាប់ពីថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០២១ តទៅរៀងរាល់ម៉ោងធ្វើការ ( ទូរស័ព្ទទាក់ទងលេខ៖ 023 67 66 007 / 092 652 357 និង Website: www.edc.com.kh ) ។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ នៅម៉ោង ១៤:00 ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០២១ ។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើវេលាម៉ោង ១៥:០៥ ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០២១ ។

ក្រុមហ៊ុន/សហគ្រាសដែលចូលរួមដាក់ឯកសារដេញថ្លៃ ស្នើសុំភ្ជាប់បន្ថែមមកជាមួយនូវឯកសារដេញថ្លៃ ដែលបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម និងភ្ជាប់មកជាមួយនូវ Soft Copy ដែលជាឯកសារ Scan របស់ឯកសារដេញថ្លៃនេះ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នាឬមានប្រភពតែមួយអាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ថ្ងៃអង្គារ ១០កើត ខែ ចេត្រ ឆ្នាំ ជូត ទោស័ក ព.ស២៥៦៤
រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០២១
ជ. ប្រធានគណៈកម្មាធិការលទ្ធកម្ម

**ហង់_ឆ្វេច**

ចម្លងជូន៖
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ
-ឯកសារ-កាលប្បវត្តិ